ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
******

តុលាការកំពូល
សភាផ្នែកព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ០៥
ចុះថ្ងៃទី៦ ខែមករា ឆ្នាំ១៩៩៨

សាលដីកា
លេខ ៣៤
ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៨

តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

---

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៨ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ ៖

| | | | |
|---|---|---|---|
| ១_ | ឯកឧត្តម | ឌិត មុន្ទី | ប្រធាន |
| ២_ | លោក | ឈឹម ស៊ីផល | ចៅក្រម_របាយការណ៍ |
| ៣_ | លោក | សោម សិរីវឌ្ឍ | ចៅក្រម |
| ៤_ | លោក | ប្រាក់ គឹមសាន | ចៅក្រម |
| ៥_ | លោក | យស់ សួខឿន | ចៅក្រម |

ក្រឡាបញ្ជី លោក ប៉ុល វណ្ណា

តំណាងមហាអយ្យការ លោក ប៉ែន សារឿន ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ១៨៥ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ៥ ចុះថ្ងៃទី៦ ខែមករា ឆ្នាំ១៩៩៨ របស់តុលាការកំពូល ។

ពីបទៈ ប៉ុនប៉ងធ្វើមនុស្សឃាដដោយគិតទុកជាមុនប្រព្រឹត្តនៅភូមិក្រពើហា ឃុំព្រែកឫស្សី ស្រុកតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃពី២៦_៨_៩៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣១នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

១_ ជនជាប់ចោទឈ្មោះ សួន ផល្លា (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិខ្មែរ កើតនៅភូមិទួលទំពូង ខ័ណ្ឌលេខ៧ ក្រុងភ្នំពេញ របររកស៊ីនគរបាល ខេត្តកណ្តាល ទីលំនៅសព្វថ្ងៃ ភូមិខ្ពបវែង ឃុំកំពង់សំណាញ់ ស្រុកតាខ្មៅ ខេត្តកណ្តាល និពុកឈ្មោះ គឹង ឆន(ស)

ម្តាយឈ្មោះ ជា ធឿន(រ) ប្រពន្ធឈ្មោះឈិន សី មានកូន៥នាក់ ។ ចាប់ខ្លួនថ្ងៃទី១៧_១០_១៩៩៦ ។

មានមេធាវី លោក សែម ចិន្តា ការពារឱ្យជនជាប់ចោទ ។

២_ ជនជាប់ចោទឈ្មោះអ៊ួន ចាន់ថន ហៅ អ៊ិត ភេទប្រុស អាយុ២៩ឆ្នាំ ទីកន្លែងកំណើត ភូមិព្រៃបង ឃុំស្រែបែក ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ របររកស៊ី នគរបាលការពារស្នងការនគរបាលខេត្តកណ្តាល ។ ទីលំនៅសព្វថ្ងៃ ភូមិព្រែកឫស្សី ឃុំតាខ្មៅ ស្រុកតាខ្មៅ ខេត្តកណ្តាល ឪពុកឈ្មោះ សៀក គីម (ស) ម្តាយឈ្មោះ សុខ អេង (រ)ប្រពន្ធឈ្មោះ សឿង សុខុម មានកូន៣នាក់ ។ ចាប់ខ្លួនថ្ងៃទី១៧_១០_១៩៩៦ (ស្លាប់) ។

_ ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ ស្រេង ស្រឿន ( ជាចុងបណ្តឹងសាទុក្ខ ) ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ របររកស៊ីនគរបាលខេត្ត ទីលំនៅសព្វថ្ងៃភូមិ ឃុំតាខ្មៅ ស្រុកតាខ្មៅ ខេត្តកណ្តាល។

មេធាវី គ្មាន

_ តាមបណ្តឹងសាទុក្ខលេខ៣៥៩_ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ របស់ឈ្មោះ សួន ផល្លា ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ១៨៥ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៧របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

_ តាមរបាយការណ៍បូកសរុបរបស់ស្នងការដ្ឋាននគរបាល ខេត្តកណ្តាល ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៩៦ ថា ៖

នៅរដូវចូលឆ្នាំខ្មែរ ឆ្នាំ១៩៩៦ ជនរងគ្រោះឈ្មោះ លី វណ្ណា មានទំនាស់យ៉ាងខ្លាំងជាមួយគ្រួសារជនល្មើស ឈ្មោះអ៊ួន ចាន់ថន ហៅអ៊ិត អំពីបញ្ហាលក់ដូរ ។ ក្រោយពេលមានទំនាស់គ្នាមកគ្រួសារទាំងពីរចេះតែ ចោះពាក្យបញ្ឆិតបញ្ឆៀងគ្នាទៅវិញទៅមក។ លុះដល់ថ្ងៃទី១៥_៨_៩៦ឈ្មោះអ៊ិតនិងឈ្មោះផល្លា បានជាយជុំគ្នានៅផ្ទះម្តាយមីងរបស់ឈ្មោះអ៊ិត(ចាយពេលយប់)។ អ្នកទាំងពីរបានពិភាក្សាគ្នាអំពីរឿងដាក់គ្រាប់បែកសម្លាប់ឈ្មោះស្រឿន និង គ្រួសារ ដោយឈ្មោះអ៊ិត ជាអ្នកផ្តើមគំនិត ចំណែកឈ្មោះផល្លា ជាអ្នកដែលដល់ក្នុងការដាក់គ្រាប់បែកដោយឈ្មោះអ៊ិត បាននិយាយធានាជួយផ្តល់លុយកាក់និងកន្លែងរកស៊ីដល់គ្រួសាររបស់ឈ្មោះផល្លានៅពេលណាធ្វើការនោះសំរេច ។ ការពិភាក្សាគ្នា២ថ្ងៃទើបឈ្មោះផល្លា យល់ព្រម ។

នៅថ្ងៃទី១៩_៨_៩៦ឈ្មោះអ៊ិត បានជួបឈ្មោះផល្លា ពិភាក្សាគ្នា និងបានប្រាប់ចំណុចកន្លែងបង្កប់គ្រាប់បែក ។ បន្ទាប់មកថ្ងៃទី២៥_៨_៩៦ វេលាម៉ោង១,១៥នាទី យប់ ឈ្មោះផល្លា បានយកគ្រាប់ដែលឈ្មោះអ៊ិត ប្រគល់ឱ្យទៅចងបង្កប់នៅទ្វារផ្ទះរបស់ឈ្មោះស្រេង ស្រឿន តាមការកំណត់របស់ឈ្មោះអ៊ិត។ លុះដល់ថ្ងៃទី២៦_៨_៩៦ វេលាម៉ោង៥,៥០នាទី ឈ្មោះលី វណ្ណា ប្រពន្ធរបស់ឈ្មោះ ស្រេង ស្រឿន ចេញមកបើកទ្វារផ្ទះ ពេលនោះគ្រាប់បែកដែលឈ្មោះផល្លាចងបង្កប់ទុក ក៏ផ្ទុះតែម្តង បណ្តាលឱ្យត្រូវរបួសឈ្មោះ លី វណ្ណា និងកូនប្រុសឈ្មោះ ស្រឿន ដារុន ជាទម្ងន់ ។

- តាមពាក្យបណ្តឹងចុះថ្ងៃទី២៦-៨-៩៦របស់ឈ្មោះស្រេង ស្រឿន ប្តឹងពីជនមិនស្គាល់មុខ ដែលយកគ្រាប់បែកមកបង្កៃនៅផ្ទះរបស់ខ្លួន ដើម្បីប៉ុនប៉ងសម្លាប់ខ្លួន ព្រមទាំងគ្រួសារ ដោយហេតុថា កាលពីថ្ងៃទី២៦-៨-១៩៩៦ ម៉ោង៥,៥០នាទី ទៀបភ្លឺ ប្រពន្ធខ្លួនបានចុះមកបើកទ្វារផ្ទះ ឯចំណែកខ្លួនក៏ដើបឡើងអង្គុយបំរុងចុះស្រាប់តែគ្រាប់បែកមួយគ្រាប់បានផ្ទុះឡើង បណ្តាលឱ្យប្រពន្ធខ្លួន និង កូនប្រុសខ្លួនដែលកំពុងដេកនៅលើផ្ទះរងរបួសជាទម្ងន់ និង ខូចខាតសំភារៈមួយចំនួនដូចជា ៖

១- ទូរសស្សន៍ ០១ គ្រឿង ធុន១៤ ពណ៌

២- ម៉ាញ៉េ ០១ គ្រឿង ធុន៤០ W

៣- អាគុប ០១ គ្រឿង បាត់ធុនP2 AT

៤- សំភារៈមួយចំនួនទៀត ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមតុលាការខេត្តកណ្តាល បានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានស្តាប់ចំលើយដោះសាររបស់ជនជាប់ចោទជនរងគ្រោះ សាក្សី និង បានពិនិត្យចំលើយសារភាពរបស់ជនជាប់ចោទនៅចៅក្រមស៊ើបអង្កេតឃើញថា មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទទាំងពីរនេះ ហើយតំណាងអយ្យការសំរេចតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ១៦ដ.ក-សព៩៧ ចុះថ្ងៃទី១៣-០២-៩៧ទុកជាបានការពេញលេញ និង សំណូមពរសុំឱ្យលោកចៅក្រមពិនិត្យពិចារណានិងសំរេចទៅតាមច្បាប់ចុះ ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ០៧"ក" ចុះថ្ងៃទី០៦ ខែមិនា ឆ្នាំ១៩៩៧របស់តុលាការខេត្តកណ្តាលដែលបានសំរេចដូចតទៅ ៖

១- ផ្តន្ទាទោសជនជាប់ចោទឈ្មោះ អ៊ួន ចាន់ថន ហៅអ៊ិត ភេទប្រុស អាយុ២៩ឆ្នាំ និងឈ្មោះ សួន ផល្លា ភេទប្រុស អាយុ៣៧ឆ្នាំ ដាក់ពន្ធនាគារ ក្នុងម្នាក់ៗកំណត់៧ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី១៧-១០-៩៦ ។ ពីបទ៖ ឃាដកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិក្រពើហា ឃុំព្រែកឫស្សី ស្រុកតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៦-៨-៩៦ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣១,៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០-៩-៩២ ។

២- វត្ថុតាងមានក្រវិលគ្រាប់បែក អំបែង៥ដុំនិងខ្សែពណ៌ត្រួយចេក១ត្រូវបំផ្លាញចោល។

៣- បង្គាប់ឱ្យជនជាប់ចោទរួមគ្នាសងសំណងការខូចខាតសំភារៈថ្លៃព្យាបាលនិងជំងឺចិត្តសរុបចំនួន២.០០០ដុល្លាអាមេរិក(ពីរពាន់ដុល្លាអាមេរិក)សុំលើសពីនោះលើកចោល ។

- ករណីរឹងទទឹងពុំព្រមសងប្រាក់ធនទណ្ឌតាមការកំណត់ខាងលើត្រូវដាក់គុកបង្ខំល្មើរូបកាយតាមបញ្ញត្តិមាត្រា៧ នៃ ច្បាប់ស្តីពីការដាក់គុកបង្ខំល្មើរូបកាយក្នុងរឿងព្រហ្មទណ្ឌដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ១៨ក្រ ចុះថ្ងៃទី០៨-២-៩២ ។

- សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទនិងជនរងគ្រោះ។ បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងរយៈពេល២ខែដោយគិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ១៦ចុះថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៩៧របស់ឈ្មោះអ៊ួន ចាន់ថន និងឈ្មោះ សួន ផល្លា ដែលប្តឹងតវ៉ាពីសាលក្រមព្រហ្មទណ្ឌលេខ០៧"វ" ចុះថ្ងៃទី០៦ ខែមិនា ឆ្នាំ១៩៩៧ របស់តុលាការខេត្តកណ្តាល លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អម សាលាឧទ្ធរណ៍ថា ៖

១- ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៨-៣-៩៧ របស់ជនជាប់ចោទទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២- ចាត់អង្កេតតាមការអះអាងរបស់ជនជាប់ចោទថាមានការបង្ខិតបង្ខំនិងគំរាមឱ្យឆ្លើយមុនពេលឆ្លើយនៅចំពោះមុខចៅក្រមស៊ើបអង្កេត ។

៣- កែប្រែត្រង់ចំណុចទី១ នៃសេចក្តីសំរេចរបស់សាលក្រមខាងលើដោយ

- កែប្រែបទចោទលើឈ្មោះ អ៊ួន ចាន់ថន ពីបទៈ ឃាដកម្មគិតទុកជាមុនមកជាបទសមគំនិតធ្វើឃាដកម្មគិតទុកជាមុនតាមមាត្រា៦៩, ៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- កែប្រែបទចោទលើឈ្មោះ សួន ផល្លា ពីបទៈ ឃាដកម្មគិតទុកជាមុនមកជាបទប៉ុនប៉ងធ្វើឃាដកម្មគិតទុកជាមុន តាមបញ្ញត្តិមាត្រា៣១នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលក្រៅពីនេះតម្កល់ទុកជាបានការ បើសិនគ្មានភស្តុតាងផ្ទុយ ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១៨៥ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ដែលបានសំរេច ៖

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍របស់ឈ្មោះសួន ផល្លា ចុះថ្ងៃទី១៨-៣-១៩៩៧ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២- ទទួលពាក្យបណ្តឹងឧទ្ធរណ៍របស់ឈ្មោះអ៊ួន ចាន់ថន ចុះថ្ងៃទី១៨-៣-១៩៩៧ ទុកជាត្រឹមត្រូវតាមទំរង់និងគតិច្បាប់ ។

៣- ចំណុចទី១នៃសាលក្រមលេខ០៧ ចុះថ្ងៃទី៦-៣-១៩៩៧របស់តុលាការខេត្តកណ្តាល ត្រង់ឃ្លាថា "ឈ្មោះអ៊ួន ចាន់ថន ហៅអ៊ិត ភេទប្រុស អាយុ២៩ឆ្នាំ និងចំណុចទី៣ ត្រង់ពាក្យថា " រួមគ្នា " ត្រូវបដិសេធចោលនិងចំណុចទី១ នៃសាលក្រមខាងលើត្រង់ពាក្យថា " ក្នុងម្នាក់ៗកំណត់៧ឆ្នាំ "ត្រូវកែប្រែថា "កំណត់៦ឆ្នាំ វិញ ។ ក្រៅពីនេះតម្កល់ទុកជាបានការដដែល ។

៤- ឱ្យឈ្មោះអ៊ួន ចាន់ថន ហៅអ៊ិត រួចផុតពីបទចោទពីបទឃាដកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិក្រពើហា ឃុំព្រែកឫស្សី ស្រុកតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទូ២៦-៨-៩៦បទល្មើសមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- បង្គាប់ឱ្យដោះលែងឈ្មោះអ៊ួន ចាន់ថន ហៅអ៊ិត ភ្លាមបើឈ្មោះនេះមិនត្រូវបាន

ជាប់ឃុំឃាំងពីបទចោទផ្សេងទៀតទេ យោងតាមបញ្ញត្តិមាត្រា១៩៦ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌនិង មាត្រា២៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៥- សាលដីកានេះ ប្រកាសជាសាធារណៈចំពោះមុខអ្នកការពារឱ្យជនជាប់ចោទនិង ដើមបណ្តឹងរដ្ឋប្បវេណី នៅថ្ងៃទី១០-៩-១៩៩៧ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសាទុក្ខលេខ៣៩៩ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ របស់ជនជាប់ ចោទឈ្មោះសួន ផល្លា ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ១៨៥ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសារណាចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៩៨ របស់ឈ្មោះសួន ផល្លា (ជាម្ចាស់បណ្តឹងសាទុក្ខ) ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានឃើញសារណាតបចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩៨ របស់ឈ្មោះស្រេង ស្រឿន (ជាចុងបណ្តឹងសាទុក្ខ) ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានស្តាប់អំណានសាវតាជាតិ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះស្រេង ស្រឿន ជា (ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះ ។

- បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អម តុលាការកំពូល ថាៈ

១- បណ្តឹងសាទុក្ខរបស់ឈ្មោះសួន ផល្លា ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើក យកមកពិនិត្យពិចារណា ។

២- បដិសេធសាលដីកាព្រហ្មទណ្ឌលេខ១៨៥ ចុះថ្ងៃទី១០-៩-៩៧ របស់ សាលាឧទ្ធរណ៍ចោលជាអសាបង់ ។

- បានស្តាប់អំណានសារណារបស់ឈ្មោះស្រេង ស្រឿន (ជាចុងបណ្តឹងសាទុក្ខ)នៅ ពេលជំនុំជំរះ ។

- បានស្តាប់ចំលើយដោះសាររបស់ជនជាប់ចោទឈ្មោះសួន ផល្លា (ជាម្ចាស់បណ្តឹង សាទុក្ខ) នាពេលជំនុំជំរះថា ៖ ខ្ញុំបាទអត់ដឹងអ្វីទាំងអស់អត់ចេះប្រើគ្រាប់ទេ ហើយក៏មិនបាន ទៅលេងផ្ទះមីងនៅតាខ្មៅដែរ កាលនៅនគរបាលគេបង្ខំឱ្យខ្ញុំនិងឈ្មោះអ៊ួន ចាន់ថន ឆ្លើយ សារភាព ចាប់ខ្ញុំបាទនៅកណ្តាលផ្លូវតែម្តង គឺខ្ញុំបាទពុំបានដឹងទេ សូមតុលាការជួយរកយុត្តិធម៌។

- បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់លោក សែម ចិន្តា ជាមេធាវីការពារឱ្យជន ជាប់ចោទឈ្មោះសួន ផល្លា (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា ៖ គ្មានភស្តុតាង គ្រប់គ្រាន់បញ្ជាក់ថា កូនក្តីខ្ញុំបាទប្រព្រឹត្តអំពើធ្វើមនុស្សឃាដគិតទុកជាមុននោះទេ ព្រោះថា តាម ពាក្យបណ្តឹងរបស់ឈ្មោះស្រេង ស្រឿន ប្តឹងពីជនមិនស្គាល់មុខ ហើយផ្អែកតាមចំលើយបង្ខិតបង្ខំ

ជនល្មើសតែម្នាក់នៅនគរបាលមិនអាចយកជាការបានឡើយ ។ ម្យ៉ាងទៀតការចាប់ខ្លួនកូនក្តីខ្ញុំបាទ គ្មានដីកាចាប់ខ្លួនពីតុលាការទេ ។ ដូច្នេះសូមតុលាការដោះលែងឱ្យមានសេរីភាព និងសូមបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ ហើយសូមទាមទារទ្រព្យសម្បត្តិដែលតុលាការថ្នាក់ក្រោមរឹបអូសប្រគល់ជូនគ្រួសារកូនក្តីខ្ញុំបាទវិញ ។

- បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមនាពេលសវនាការរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា ៖ សូមរក្សាសេចក្តីសន្និដ្ឋាននៅដដែល ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប់ចំលើយដោះសាររបស់ជនជាប់ចោទ សារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ .

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ .

## តុលាការកំពូល

- យល់ឃើញថាបណ្តឹងសាទុក្ខលេខ៣៥៩ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ របស់ឈ្មោះសួន ផល្លា ធ្វើឡើងក្នុងកំណត់ច្បាប់ ។ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចឱ្យឈ្មោះអ៊ួន ចាន់ថន ហៅអ៊ិត រួចផុតពីបទចោទ និងផ្តន្ទាទោសឈ្មោះសួន ផល្លា ដោយអាងហេតុថាឈ្មោះអ៊ួន ចាន់ថន ហៅអ៊ិត គ្មានពិរុទ្ធភាព រីឯឈ្មោះសួន ផល្លា ពិតជាមានពិរុទ្ធភាពពីបទប៉ុនប៉ងធ្វើមនុស្សឃាដ ដោយចេតនា នោះជាការពុំត្រឹមត្រូវឡើយ ពីព្រោះថា៖ ភស្តុតាងដើម្បីចោទប្រកាន់លើជនទាំងពីរគឺ សំអាងទៅលើចំលើយសារភាពរបស់សាមីខ្លួនតែប៉ុណ្ណោះដូចមាននៅក្នុង-កំណត់ហេតុសួរចំលើយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៩៦ ឈ្មោះអ៊ួន ចាន់ថុន បានឆ្លើយសារភាពថាខ្លួនមានទំនាក់ទំនងជាមួយឈ្មោះសួន ផល្លា ហើយបានប្រាប់ឱ្យឈ្មោះសួន ផល្លាដាក់បង្កើគ្រាប់បែកនៅមុខផ្ទះឈ្មោះស្រេង ស្រឿន ដូច្នេះអ្នកទាំងពីរត្រូវមានពិរុទ្ធភាពដូចគ្នាបើគ្មានពិរុទ្ធក៍ត្រូវគ្មានដូចគ្នាដែរ ។

- យល់ឃើញថាជនជាប់ចោទបានប្តឹងសុំបដិសេធចំលើយសារភាពរបស់ខ្លួននៅចំពោះមុខនគរបាលក៍ដូចនៅចំពោះមុខចៅក្រមស៊ើបអង្កេតដោយអាងហេតុថា៖ ចំលើយទាំងនោះបានមកដោយការបង្ខិតបង្ខំ ប៉ុន្តែសាលាឧទ្ធរណ៍មានការខ្វះខាតដោយពុំបានពិចារណានឹងសំរេចអំពីពាក្យសុំនោះទេ ។

- យល់ឃើញថាទាំងសាលាឧទ្ធរណ៍ ទាំងតុលាការខេត្តកណ្តាលមានការខ្វះខាត ដោយពុំបានសំរេចអំពីសំភារៈប្រើប្រាស់ដូចជាកង់មីគី១គ្រឿងពណ៌ក្រហម នាឡិកាដៃមីដូ ១គ្រឿង អាគុយពាកា ១គ្រឿង ប្រើបានដែលពុំមែនជាវត្ថុតាងយកទៅប្រព្រឹត្តបទល្មើសឡើយ។

- យល់ឃើញថាសាលាឧទ្ធរណ៍មានការខុសឆ្គងដូចការលើកឡើងរបស់មេធាវីជនជាប់ចោទនាសវនាការនេះថាសាលាឧទ្ធរណ៍សំរេចសេចក្តីក្នុងរឿងឧក្រិដ្ឋដោយពុំបានចាត់តាំងមេធាវីឱ្យជនជាប់ចោទឈ្មោះសួន ផល្លា តាមមាត្រា១០នៃច្បាប់ព្រហ្មទណ្ឌ អន្តរកាល ។

- យល់ឃើញថាដើមបណ្តឹងរដ្ឋប្បវេណី បានផ្ញើសារណាជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានចូលរួមនាសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថាសាលដីកាព្រហ្មទណ្ឌ លេខ១៨៥ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានការខុសឆ្គងទាំងទំរង់ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

### វិនិច្ឆ័យសេចក្តីចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ

១- ទទួលបណ្តឹងសាទុក្ខលេខ៣៥៩ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧របស់ឈ្មោះសួន ផល្លា ទុកជាត្រឹមត្រូវតាមទំរង់និងគតិច្បាប់ ។

២- ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌ លេខ១៨៥ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣- បង្វិលសំណុំរឿងព្រហ្មទណ្ឌ លេខ០៥ ចុះថ្ងៃទី៦ ខែមករា ឆ្នាំ១៩៩៨ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៨៕